មេរៀនទី១៤

# របៀបដែលស្មរបន្ទាល់ព្រះយេហូវ៉ា បានត្រូវរៀបចំឡើង

***តើការចាប់ផ្ដើមសម័យទំនើបរបស់ស្មរបន្ទាល់ព្រះយេហូវ៉ាកើតឡើងនៅពេលណា? (១)***

***តើការប្រជុំរបស់ស្មរបន្ទាល់ព្រះយេហូវ៉ាប្រព្រឹត្តឡើងដូចម្ដេច? (២)***

***តើចំណាយត្រូវជួយចេញយ៉ាងដូចម្ដេច? (៣)***

***តើអ្នកណាជាអ្នកនាំមុខក្នុងក្រុមជំនុំនិមួយៗ? (៤)***

***តើមានការប្រជុំធំៗអ្វីខ្លះរៀងរាល់ឆ្នាំ? (៥)***

***តើកិច្ចការអ្វីដែលគេធ្វើនៅមជ្ឈមណ្ឌលនិងការិយាល័យសាខារបស់គេ? (៦)***

១. ការចាប់ផ្ដើមសម័យទំនើបរបស់ស្មរបន្ទាល់ព្រះយេហូវ៉ា គឺកើតឡើងក្នុងរវាងឆ្នាំ១៨៧០ និង១៨៧៩ ។ ដំបូង ពួកគេមានឈ្មោះហៅថាជាសិស្សព្រះគម្ពីរ ។ ប៉ុន្តែនៅឆ្នាំ១៩៣១ ពួកគេជ្រើសយកឈ្មោះស្មរបន្ទាល់ព្រះយេហូវ៉ាតាមបទគម្ពីរ ។ (អេសាយ ៤៣:១០) អង្គការនេះបានលូតលាស់ពីដំបូងដែលមានគ្នាមួយក្រុមតូចរហូតដល់កើនបានចំនួនស្មរបន្ទាល់រាប់លាននាក់ ដែលមានកិច្ចរវល់ក្នុងការផ្សាយប្រកាសក្នុងជាង២៣០ប្រទេស ។



២. ក្រុមជំនុំភាគច្រើនរបស់ស្មរបន្ទាល់ព្រះយេហូវ៉ាមានប្រជុំបីដងរៀងរាល់សប្ដាហ៍ ។ ពួកគេសូមអញ្ជើញឲ្យអ្នករាល់គ្នាចូលរួមក្នុងប្រជុំទាំងនេះ ។ (ហេព្រើរ ១០:២៤, ២៥) ព្រះគម្ពីរគឺជាមូលដ្ឋាននៃការបង្រៀន ។ ការប្រជុំគឺចាប់ផ្ដើមឡើងហើយបញ្ចប់ដោយសេចក្ដីអធិស្ឋាន ។ «ចំរៀងវិញ្ញាណ» ដ៏ជ្រាលជ្រៅក្នុងចិត្តក៏មានច្រៀងដែរក្នុងប្រជុំភាគច្រើន ។ (អេភេសូរ ៥:១៨, ១៩) ឯប្រជុំនោះគឺអាចចូលរួមដោយឥតបាច់បង់ថ្លៃ ហើយឥតមានការប្រមូលយកប្រាក់អ្វីទាំងអស់ ។—ម៉ាថាយ ១០:៨

៣. ក្រុមជំនុំភាគច្រើនមានប្រជុំក្នុងសាលព្រះរាជាណាចក្រ ដែលធម្មតាជារោងដ៏ស្រួលឥតស្មុគស្មាញ សង់ឡើងដោយពួកស្មរបន្ទាល់ស្ម័គ្រចិត្ត ។ អ្នកនឹងឃើញថាឥតមានបដិមាករ រូបព្រះយេស៊ូឆ្កាង ឬរបស់អ្វីៗដូចនេះឡើយនៅសាលព្រះរាជាណាចក្រ ។ ចំណាយទាំងប៉ុន្មានគឺជួយចេញដោយប្រាក់អំណោយពីពួកអ្នក







ស្ម័គ្រចិត្ត ។ មានប្រអប់វិភាគទានសំរាប់ពួកអ្នកដែលប្រាថ្នាចង់ធ្វើអំណោយ ។ —កូរិនថូសទី២ ៩:៧

៤. នៅក្នុងក្រុមជំនុំនិមួយៗមានពួកអ្នកចាស់ទុំឬពួកអ្នកមើលខុសត្រូវ ។ ពួកគេនាំមុខក្នុងការបង្រៀនក្នុងក្រុមជំនុំ ។ (ធីម៉ូថេទី១ ៣:១-៧; ៥:១៧) ពួកគេគឺមានពួកអ្នកបំរើជំនួយជួយផ្គត់ផ្គង់ ។ (ធីម៉ូថេទី១ ៣:៨-១០, ១២, ១៣) បុរសទាំងនេះឥតមានបុណ្យសក្តិអ្វីខ្ពស់ជាងអ្នកផងទាំងពួងក្នុងក្រុមជំនុំទេ ។ (កូរិនថូសទី២ ១:២៤) ពួកគេឥតមានទទួលមុខតំណែងពិសេសអ្វីទាំងអស់ ។ (ម៉ាថាយ ២៣:៨-១០) ពួកគេស្លៀកពាក់មិនខុសពីអ្នកឯទៀតឡើយ ហើយធ្វើកិច្ចការក៏ឥតទទួលប្រាក់ខែដែរ ។ ពួកចាស់ទុំសុខចិត្តមើលថែទាំសេចក្តីត្រូវការខាងវិញ្ញាណនៃក្រុមជំនុំ ។ ពួកគេអាចផ្តល់នូវការសម្រាលទុក្ខនិងការណែនាំក្នុងគ្រាមានវិបត្តិផង ។ —យ៉ាកុប ៥:១៤-១៦; ពេត្រុសទី១ ៥:២, ៣

៥. ស្មរបន្ទាល់ព្រះយេហូវ៉ាក៏មានសន្និបាតធំៗឬមហាសន្និបាតរាល់ឆ្នាំដែរ ។ ក្នុងវេលានេះ ក្រុមជំនុំជាច្រើនបានមករួបរួមជាមួយគ្នាដើម្បីទទួលកម្មវិធីពិសេសអំពីសេចក្តីបង្រៀនខាងព្រះគម្ពីរ ។ ការធ្វើបុណ្យជ្រមុជទឹកនៃពួកសិស្សថ្មីៗក៏ជាចំណែកដែលមានធ្វើឡើងជារឿយៗនៃកម្មវិធីនិមួយៗនៃសន្និបាតឬមហាសន្និបាត ។—ម៉ាថាយ ៣:១៣-១៧; ២៨:១៩, ២០

៦. មជ្ឈមណ្ឌលពិភពលោករបស់ស្មរបន្ទាល់ព្រះយេហូវ៉ាគឺស្ថិតនៅទីក្រុងញូវយ៉ក ។ នៅទីនោះមានគណៈអភិបាល ជាក្រុមកណ្តាលប្រកបដោយពួកអ្នកចាស់ទុំដ៏មានការពិសោធ ដែលមើលខុសត្រូវដល់ក្រុមជំនុំក្នុងពិភពលោកទាំងមូល ។ ហើយក៏មានការិយាល័យសាខាជាងមួយរយទូទាំងពិភពលោកដែរ ។ នៅទីកន្លែងទាំងនេះ មានពួកអ្នកស្ម័គ្រចិត្តជួយបោះពុម្ពនិងដឹកជញ្ជូនសៀវភៅខាងព្រះគម្ពីរ ។ ហើយក៏មានការណែនាំប្រាប់ឲ្យចាត់ចែងកិច្ចការផ្សាយប្រកាសផងដែរ ។ ហេតុអ្វីអ្នកមិនគិតទៅលេងឯការិយាល័យសាខាដែលនៅជិតផ្ទះអ្នកម្តង ?

